# សមាគមធានារ៉ាប់រងកម្ពុជា
Insurance Association of Cambodia


## ខ្លឹមសារសង្ខេបនៃសិក្ខាសាលា ស្តីពី
## “ទីផ្សារធានារ៉ាប់រង និងឱកាសការងារ” លើកទី២







នាថ្ងៃទី២៦ ខែមីនា ឆ្នាំ២០១៦ សមាគមធានារ៉ាប់រងកម្ពុជា បានរៀបចំសិក្ខាសាលានៅតាមសាកលវិទ្យាល័យជាលើកទីពី ស្តីពី “ទីផ្សារធានារ៉ាប់រង និងឱកាសការងារ” នៅសាកលវិទ្យាល័យអាស៊ីអឺរ៉ុប ក្រោមការចូលរួមជាអធិបតីដ៏ខ្ពង់ខ្ពស់របស់លោកបណ្ឌិតសាកលវិទ្យាធិកានៃសាកលវិទ្យាល័យអាស៊ីអឺរ៉ុប និងដោយមានវាគ្មិនមកពីក្រុមហ៊ុនធានារ៉ាប់រងក្នុងស្រុក ចូលរួមចែករំលែក អំពីចំណេះដឹង

និងបទពិសោធន៍ថ្មីៗ ក្នុងគោលបំណងការលើកកម្ពស់ វិស័យធានារ៉ាប់រង ដល់សិស្សនិស្សិតនៅកម្ពុជា។ ថ្លែងក្នុងពិធីបើកសិក្ខាសាលា លោក **ហ៊ុយ វ៉ាថារ៉ូ** ប្រធានសមាគមធានារ៉ាប់រងកម្ពុជា បានគូសបញ្ជាក់ថា វិស័យធានារ៉ាប់រងត្រូវបានចាត់ទុកជាសសរស្តម្ភមួយនៃវិស័យហិរញ្ញវត្ថុ នៅក្នុងយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ ឆ្នាំ២០១១ - ២០២០ ហើយដែលបច្ចុប្បន្នកំពុងស្ថិតក្រោមការធ្វើបច្ចុប្បន្នភាព។ ទន្ទឹមនឹងការរីកចម្រើននៃទីផ្សារធានារ៉ាប់រងដ៏គួរឲ្យកត់សម្គាល់នេះ វិស័យធានារ៉ាប់រងនៅកម្ពុជា ក៏មានកង្វះតម្រូវការលើធនធានមនុស្សកាន់តែច្រើន លើជំនាញផ្សេងៗនៅក្នុងខ្សែសង្វាក់ផលិតកម្មធានារ៉ាប់រងគឺជាបញ្ហាប្រឈមមួយ។ សមាគមធានារ៉ាប់រងកម្ពុជា បាននិងកំពុងប្រឹងប្រែងគ្រប់លទ្ធភាពដើម្បីរៀបចំឲ្យបុគ្គលិកធានារ៉ាប់រងវិជ្ជាជីវៈក្នុងស្រុក មានឱកាសបង្កើនចំណេះដឹងជំនាញរបស់ខ្លួនលើគ្រប់ផ្នែក នៃខ្សែសង្វាក់អាជីវកម្មធានារ៉ាប់រង។

លោកបណ្ឌិត **ជា សុភាព** សាកលវិទ្យាធិកានៃសកលវិទ្យាល័យ អាស៊ីអឺរ៉ុប មានប្រសាសន៍ក្នុងអង្គសិក្ខាសាលាថា លោកមានសេចក្តីរីករាយណាស់ ដែលសមាគមធានារ៉ាប់រងនៃកម្ពុជា បានរៀបចំសិក្ខាសាលានេះឡើង និងបានអញ្ជើញវាគ្មិនមកពីក្រុមហ៊ុនធានារ៉ាប់រងនានាក្នុងស្រុក ដើម្បីចែករំលែកចំណេះដឹង និងបទពិសោធន៍ថ្មីៗ ក៏ដូចជាឱកាសការងារ ទាក់ទងទៅនឹងវិស័យធានារ៉ាប់ ដល់សិស្សនិស្សិតក្នុងសាកលវិទ្យាល័យរបស់លោក។ លោកសង្ឃឹមថាសិក្ខាសាលាថ្ងៃនេះ និងផ្តល់ឲ្យសិស្សនិស្សិតនូវចំណេះដឹងជាច្រើន ដើម្បីឲ្យពួកគេអភិវឌ្ឍន៍ខ្លួន ទៅក្នុងវិស័យធានារ៉ាប់រងនៅពេលដែលពួកគេបញ្ចប់ការសិក្សា។

ជាចុងបញ្ចប់លោក **ហ៊ុយ វ៉ាថារ៉ូ** សំដែងនូវអំណរអរគុណយ៉ាងជ្រាលជ្រៅចំពោះលោកបណ្ឌិត **ជា សុភាព** សាកលវិទ្យាធិកា នៃសាកវិទ្យាល័យអាស៊ី អឺរ៉ុប ដែលបានផ្តល់កិត្តិយស ចូលរួមជាអធិបតី និងផ្តល់ទីតាំងធ្វើសិក្ខាសាលា ព្រមទាំងវាគ្មិនទាំងអស់ដែលបានចំណាយពេលដ៏មានតម្លៃ រៀបចំបទបង្ហាញ និងមានវត្តមាននៅពេលនេះ និង អរគុណយ៉ាងជ្រាលជ្រៅចំពោះចំពោះក្រុមហ៊ុនធានារ៉ាប់រងហ្វតេ និងក្រុមហ៊ុនធានារ៉ាប់រង កម្ពុជា វៀតណាម ដែលបានផ្តល់ជាកាដូរ និងវត្ថុអនុស្សាវរីយ៍ដល់ដល់សិស្សនិស្សិតក្នុងការចូលរួមសិក្ខាសាលាថ្ងៃនេះ។ មុននឹងបញ្ចប់លោកសង្ឃឹមថា សិស្សានុសិស្ស និងខិតខំយកចិត្តទុកដាក់ស្តាប់ ដើម្បីទទួលបានចំណេះដឹង និងបទពិសោធន៍ល្អៗពីវាគ្មិន និងមានសមត្ថភាពចូលបម្រើការងារក្នុងវិស័យធានារ៉ាប់រងឲ្យបានច្រើន។





រាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែ មីនា ឆ្នាំ ២០១៦

**សមាគមធានារ៉ាប់រងកម្ពុជា**